# ក្រុមការពារក្តី
# ជនសង្ស័យម្នាក់នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
# **Defence Team for a Named Suspect at the ECCC**

**<u>សេចក្តីប្រកាសព័ត៌មាន ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៣</u>**

**<u>សិទ្ធិទទួលបានការកាត់ក្តីដោយយុត្តិធម៌ត្រូវរងការគំរាមកំហែងក្នុងសំណុំរឿង០០៤</u>**

វាបានលេចរូបរាងកាន់តែច្បាស់ក្នុងរយៈពេលប៉ុន្មានខែចុងក្រោយនេះថា រដ្ឋបាលអង្គការសហប្រជាជាតិ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មិនមានលទ្ធភាព ឬក៏មិនមានឆន្ទះក្នុងការផ្តល់នូវការឧបត្ថម្ភចាំបាច់ដល់ក្រុមការពារក្តីដើម្បីធានាថានឹងមានការគោរពចំពោះសិទ្ធិទទួលបានការកាត់ក្តីដោយយុត្តិធម៌របស់កូនក្តីរបស់ពួកខ្ញុំដែលជាជនសង្ស័យម្នាក់ក្នុងសំណុំរឿង០០៤។

យើងខ្ញុំ ក្នុងនាមជាសហមេធាវីសម្រាប់ជនសង្ស័យ យល់ស្របតាមការលើកឡើងរបស់សហព្រះរាជអជ្ញាជាតិ ថាកូនក្តីរបស់យើងខ្ញុំមិនមែនជាមេដឹកនាំកំពូលក្នុងរបបកម្ពុជាប្រជាធិបតេយ្យទេ ហើយគាត់ក៏មិនស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តក្នុងសម័យខ្មែរក្រហមដែរ ព្រោះថាកូនក្តីរបស់យើងខ្ញុំជាកម្មាភិបាលថ្នាក់ទាប។ ដូច្នេះកូនក្តីរបស់យើងខ្ញុំ មិនស្ថិតក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(អ.វ.ត.ក)ទេ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ល្គឹកណានិតិវិធីតុលាការនៅតែដើរ កូនក្តីយើងខ្ញុំគួរតែទទួលបាននូវសិទ្ធិទទួលបានការកាត់ក្តីដោយយុត្តិធម៌ ដែលសិទ្ធិនេះត្រូវបានធានាយ៉ាងពេញលេញនិងមិនមានលក្ខខណ្ឌសម្រាប់ជនសង្ស័យនៅមុខ អ.វ.ត.ក។ ជាលទ្ធផលចេញពីសកម្មភាព និងភាពអសកម្មជាប់ៗគ្នាមួយចំនួនរបស់រដ្ឋបាលអង្គការសហប្រជាជាតិក្នុងរយៈពេលប៉ុន្មានខែចុងក្រោយនេះ កូនក្តីយើងខ្ញុំទំនងដូចជាមិនអាច អនុវត្តន៍សិទ្ធិរបស់ខ្លួនបានឡើយ។

ជាថ្មីម្តងទៀត អង្គភាពគាំពារការការពារក្តី (DSS) បានបដិសេធមិនព្រមឧបត្ថម្ភលើការចំណាយដ៏ចាំបាច់និងសមហេតុផលសម្រាប់ការធ្វើដំណើររបស់ក្រុមក្នុងការទៅជួបកូនក្តីដើម្បីទទួលការណែនាំ និងរៀបចំការអង្កេតបឋមមួយចំនួន។ នៅក្នុងករណីបែបនេះ ពួកខ្ញុំមិនអាចចូលរួមយ៉ាងសកម្មក្នុងកិច្ចស៊ើបអង្កេត ឬក៏ការពារសិទ្ធិរបស់កូនក្តីបានទេ។

ការបដិសេធថ្មីៗនេះរបស់អង្គភាពគាំពារការការពារក្តី គឺជារូបភាពមួយនៃការរាំងស្ទះដែលបង្កឡើងដោយអង្គភាពគាំពារការការពារក្តី ដែលការរាំងស្ទះនេះចាប់ផ្តើមជាដំបូងដោយការបដិសេធ (ដោយរំលោភលើដីកាបញ្ជារបស់សហចៅក្រមស៊ើបអង្កេត) មិនព្រមទទួលស្គាល់លោក រីឆាដ រ៉ូជើ (Richard ROGERS) ជាសហមេធាវីអន្តរជាតិ។ កូនក្តីយើងខ្ញុំបានជ្រើសរើសលោកមេធាវី រីឆាដ រ៉ូជើ ជាសហមេធាវីអន្តរជាតិរបស់ខ្លួនកាលពីខែមិនា ឆ្នាំ២០១២។ ឥឡូវនេះ បញ្ហាស្នូលថ្មីមួយទៀតបានកើតឡើងដោយការបដិសេធ

របស់អង្គភាពគាំពារការការពារក្ដី ក្នុងការអនុញ្ញាតការធ្វើដំណើរដល់សហមេធាវីអន្តរជាតិម្នាក់ផ្សេងទៀតក្នុងក្រុម គឺលោក ហ្គោរេន ស្លាវធើ (Göran SLUITER) ដែលលោកមានទីស្នាក់ការនៅជាមួយការិយាល័យមេធាវី បូលរ័ នៅទីក្រុងអាមស្ទើដាម ប្រទេសហូល្លង់ ។ ការស្នើសុំការធ្វើដំណើរដាក់ដោយ លោកមេធាវីស្លាវធើ ធ្វើឡើងក្នុងបំណងថា លោកជាមួយនិងសហសេវិកក្នុងក្រុមការពារក្ដី (សម្រាប់ជនសង្ស័យម្នាក់ក្នុងសំណុំរឿង០០៤) ដែលមានទីស្នាក់ការនៅ អ.វ.ត.ក អាចពិភាក្សាបញ្ហាច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិសាំញ៉ាំមួយចំនួនទាក់ទិននឹងសំណុំរឿង រួមទាំងការរៀបចំផែនការ និងការបំពេញការស៊ើបអង្កេតរកភស្តុតាងដោះបន្ទុកនៅក្នុងប្រទេសកម្ពុជា។ វានឹងមិនមានសិទ្ធិទទួលបានការកាត់ក្ដីដោយយុត្តិធម៌ទៀតទេ ប្រសិនបើអាជ្ញាធររដ្ឋបាលអង្គការសហប្រជាជាតិ ដកហូតនូវសិទ្ធិរបស់កូនក្ដីក្នុងការទទួលបាននូវជំនួយផ្នែកច្បាប់ដែលមានប្រសិទ្ធិភាព។

ក្រុមការពារក្ដី បានដឹងយ៉ាងច្បាស់ពីវិបត្តិហិរញ្ញវត្ថុដែល អ.វ.ត.ក កំពុងជួបប្រទះ។ ប៉ុន្តែហេតុផលស្របច្បាប់តែមួយគត់ដែលឆ្លើយតបទៅនឹងបញ្ហាថវិកា និងបញ្ហាប្រឈមផ្សេងទៀតទាក់ទិននឹងយុត្តិធម៌ឧក្រិដ្ឋកម្ម ត្រូវបានបកស្រាយដោយចៅក្រមនៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (ICTY) គឺចៅក្រម ហាន់ ដូចខាងក្រោម៖

*"សហគមន៍អន្តរជាតិ បានផ្ដល់ការទុកចិត្តដល់តុលាការ[ឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី] ក្នុងការនាំខ្លួនជនត្រូវចោទលើការរំលោភយ៉ាងធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិមកកាត់ទោស។ សហគមន៍អន្តរជាតិ រំពឹងថាតុលាការ[ឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី]នឹងបំពេញភារកិច្ចនេះ ដោយគោរពចំពោះសិទ្ធិ[នានា]របស់ជនជាប់ចោទ [...]។ ប្រសិនបើសហគមន៍អន្តរជាតិមិនបានផ្ដល់ពេលវេលានិងថវិការគ្រប់គ្រាន់ដល់តុលាការដើម្បីបំពេញភារកិច្ចនេះទេ អញ្ចឹងសហគមន៍អន្តរជាតិ គួរតែកុំរំពឹងយកជនទាំងនោះមកធ្វើការកាត់ទោសតាមវិធីដែលមិនបានគោរពសិទ្ធិ[របស់ជនជាប់ចោទ]ទាំងនោះអី។"*[1]

ប្រសិនបើ អ.វ.ត.ក ខ្វះធនធាន[ថវិកា] ដើម្បីផ្ដល់ការឧបត្ថម្ភសមរម្យមួយដល់ក្រុមការពារក្ដីសំណុំរឿងប្រឆាំងនឹងកូនក្ដីយើងខ្ញុំ គួរតែត្រូវបានតម្កល់ទុកមិនចាត់ការទៅ។ ប្រសិនបើអង្គភាពគាំពារការការពារក្ដី នៅតែរក្សាជំហររារាំងដដែលទេ យើងខ្ញុំនឹងចាត់វិធានការបន្ទាប់ទៀត រួមទាំងការដាក់សំណើស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតតម្កល់រឿងទុកមិនចាត់ការ ដោយឈរលើហេតុផលថា អ.វ.ត.ក មិនអាចផ្ដល់នូវសិទ្ធិទទួលបានការកាត់ក្ដីដោយយុត្តិធម៌ដល់កូនក្ដីយើងខ្ញុំទេ។

ព័ត៌មានបន្ថែម សូមទាក់ទងលោក ហ្គោរេន ស្លាវធើ Göran Sluiter តាមរយៈអ៊ីម៉ែល ៖ gsluiter@bohler.eu

សហមេធាវី

មុំ លុជ្ស
Richard ROGERS
Göran SLUITER

---

[i] តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (ICTY), មតិជំទាស់របស់ចៅក្រម David Hunt លើការទទួលយកភស្តុតាងដែលបង្ហាញដោយភាគីជាម្ចាស់ក្នុងទម្រង់ជាកំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរ, *រឿងក្តីរដ្ឋអជ្ញាតទល់នឹង Milošević,* ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០៣, កថាខណ្ឌ ២២, គូសបញ្ជាក់បន្ថែម។